**និយ័តករបរធនបាលកិច្ច**

**TRUST REGULATOR**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង ន.ប.ធ. ស្តីពី “នីតិវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ ន.ប.ធ. និងគោលការណ៍ណែនាំអំពីបែបបទនិងទម្រង់លិខិតរដ្ឋបាលរបស់ ន.ប.ធ. ” ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃចន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ព្រះសីហនុ, ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២

នៅសណ្ឋាគារ ឆ្នេរសុខា (Sokha Beach) ខេត្តព្រះសីហនុ

នៅព្រឹកថ្ងៃចន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី “**នីតិវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ ន.ប.ធ. និងគោលការណ៍ណែនាំអំពីបែបបទនិងទម្រង់លិខិតរដ្ឋបាលរបស់ ន.ប.ធ.**” ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២២ នៅសណ្ឋាគារឆ្នេរសុខា (Sokha Beach) ខេត្តព្រះសីហនុ។

សិក្ខាសាលានេះ បានរៀបចំឡើងក្នុងគោលបំណង ដើម្បីជួយសម្រួលដល់មន្ត្រីរបស់ **ន.ប.ធ.** ក្នុងការរៀបចំលិខិតរដ្ឋបាលនានារបស់ **ន.ប.ធ.** ឱ្យមានភាពច្បាស់លាស់, ឆាប់រហ័ស និងមានស្តង់ដារួមគ្នាមួយ ព្រមទាំងបង្កើតឱ្យមាននូវសណ្តាប់ធ្នាប់ទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** តាមរយៈមុខងារដែលបានបង្កើតនៅក្នុងប្រព័ន្ធ ជាពិសេសជួយកាត់បន្ថយលើកិច្ចការគ្រប់គ្រងទិន្នន័យមន្ត្រីរបស់ **ន.ប.ធ.** តាមបែបលើក្រដាស (Paper Base) ផងដែរ។